CAMBREW LTD
Part of the Carlsberg Group

# អបអរសាទរខួប ១៧៥ឆ្នាំ




# ៣០ឆ្នាំ












CAMBREW LTD
Part of the Carlsberg Group

១៥-ធ្នូ-២០២២ /លេខ៖ CAMNOV2022#1

# អបអរសាទរខួប ១៧៥ឆ្នាំ របស់ស្រាបៀរកាសស៊្បែរ




រយៈពេល ១៧៥ ឆ្នាំមកហើយ ចាប់តាំងពីចាប់ផ្តើមនៃដំណើរការរបស់កាសស្បែរក្នុងទីផ្សារ។ យើងទទួលបានបទពិសោធ ឧបសគ្គ និងភាពជោគជ័យ ដែលនាំឲ្យស្រាបៀររបស់យើង បានក្លាយជាស្រាបៀរនាំមុខគេមួយនៅក្នុងឧស្សាហកម្មស្រាបៀរ។ យើងទាំងអស់គ្នា ជាសហសេវិករបស់កាសស៊្បែរ ពិតជាស័ក្តិសម នឹងទទួលបាននូវការទះដៃអបអរសាទរ សម្រាប់កិច្ចខិតខំប្រឹងប្រែង និងការលះបង់របស់យើង។

**#ក្រុមការងារដែលនៅពីក្រោយការផលិតស្រាបៀររបស់យើង!**

## ខួប ១៧៥ ឆ្នាំ ក៏បញ្ជាក់ពីការគោរព ស្ងើចសរសើរចំពោះយើងទាំងអស់គ្នា ដែលនៅពីក្រោយការកសាងពាណិជ្ជសញ្ញាស្រាបៀរ ដែលទំនងជាស្រាបៀរល្អបំផុតនៅក្នុងពិភពលោក។



ថ្ងៃសុក្រ ទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ យើងបានប្រារព្ធពិធីអបអរនៃការបោះជំហានរបស់ក្រុមហ៊ុន និងក្រុមការងារដែលនៅពីក្រោយភាពជោគជ័យ នៃការផលិតស្រាបៀររបស់យើង។ អគ្គនាយកគ្រប់គ្រងខេមប្រ៊ូវ Vladimir បានចែករំលែកនូវរឿងរ៉ាវជំរុញទឹកចិត្ត និងប្រវត្តិកំណើតនៃការផលិតស្រាបៀរកាសស្បឺរ។ Vlad បានលើកឡើងពីភាពធន ភាពរឹងមាំ និងការចូលរួមចំណែករបស់សហសេវិក នៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន ក៏ដូចជាបង្ហាញពីជំនឿចិត្តយ៉ាងមុតមាំរបស់លោក ទៅលើសមត្ថភាពបុគ្គលិក ថា

ពួកគេពិតជាអាចជំរុញឲ្យស្រាបៀររបស់យើង មានភាពរីកចម្រើនជានិរន្តរភាពនៅក្នុងទីផ្សារ។





សហសេវិក ខេមប្រ៊ូវ ចូលរួមអបអរនឹងភាពជោគជ័យនេះ និងបានលើកកំប៉ុងស្រាបៀរកាសស៊្បែររូបរាងកំប៉ុង ដើម្បីអបអរសាទរចំពោះភាពជោគជ័យនេះ។ នាឱកាសដ៏រំភើបនេះ សហសេវិកបានកាត់នំខេកកាសស៊្បែររួមគ្នា រីករាយជាមួយអាហារសម្រន់ ភេសជ្ជៈ និងផ្ដិតយកទិដ្ឋភាពដ៏រីករាយបំផុតជាមួយមិត្តរួមការងារ ថ្នាក់ដឹកនាំ ព្រមជាមួយនឹងស្តង់ថតរូបនៃខួប ១៧៥ឆ្នាំ របស់យើង។





ដើម្បីអបអរសាទរព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ កាលពីខែតុលា ឆ្នាំ២០២២ យើងក៏បានបង្ហាញរូបរាងកំប៉ុងស្រាបៀរកាសស្បឺរមានចំនួនកំណត់ចំនួនបួនរចនាបថផ្សេងគ្នា ដែលកំប៉ុងនីមួយៗ ពោរពេញដោយភាពច្នៃប្រឌិត និងបង្កប់នូវអត្ថន័យដ៏ជ្រាលជ្រៅ។
យើងមានមោទកភាព ដែលបានក្លាយជាចំណែកមួយក្នុងភាពជោគជ័យមួយនេះ។




**#អបអរសាទរដល់យើងទាំងអស់គ្នា ដែលនៅពីក្រោយភាពជោគជ័យរបស់កាសស្បឺរ!**

**#អបអរសាទរភាពជោគជ័យរបស់យើង!**

# កិច្ចប្រជុំស្តីពីបច្ចុប្បន្នភាពអាជីវកម្ម របស់ខេមប្រ៊ូវ



ការធ្វើបច្ចុប្បន្នភាពអាជីវកម្មដោយផ្ទាល់ នៅគ្រប់តំបន់លក់ទាំងអស់របស់ ខេមប្រ៊ូវ គឺជាយុទ្ធសាស្ត្រអាជីវកម្ម និងអាទិភាពមួយរបស់ក្រុមហ៊ុន។ ការធ្វើបច្ចុប្បន្នអាជីវកម្មនេះ មានគោលដៅសំខាន់ដើម្បីធានាថា សហសេវិកទាំងអស់របស់ ខេមប្រ៊ូវ ទទួលបានព័ត៌មាន និងការធ្វើបច្ចុប្បន្នអំពីការអភិវឌ្ឍ វឌ្ឍនភាព និងការរីកចម្រើនរបស់ក្រុមហ៊ុន ក៏ដូចជាបង្កើនការចូលរួមរបស់សហសេវិក ក្នុងការអនុវត្តយុទ្ធសាស្ត្រអាជីវកម្ម ក៏ដូចជាផ្សារភ្ជាប់ និងរក្សាទំនាក់ទំនងពួកយើងជាបុគ្គលិកបានយ៉ាងស័ក្តិសិទ្ធភាព។

កាលពីថ្ងៃទី១៥ ដល់ថ្ងៃទី១៨ ខែវិច្ឆិកា ថ្នាក់ដឹកនាំរបស់ ខេមប្រ៊ូវ បានរៀបចំកិច្ចប្រជុំ ស្តីពីបច្ចុប្បន្នភាពអាជីវកម្មដល់សហសេវិក នៅតាមតំបន់លក់ ដូចជា ខេត្តកំពង់ចាម បាត់ដំបង ក្រុងព្រះសីហនុ សៀមរាប និងនៅរាជធានីភ្នំពេញ។ សហសេវិកនៅតាមបណ្តាខេត្ត-រាជធានីទាំងអស់ បានចូលរួមកិច្ចប្រជុំនេះ និងបានដឹងពីបច្ចុប្បន្នភាពយុទ្ធសាស្ត្រអាទិភាព ស្ថានភាពអាជីវកម្ម និងបញ្ហាប្រឈមចម្បង ក៏ដូចជាគន្លឹះជោគជ័យក្នុងទីផ្សារ។









សហសេវិករបស់យើង ក៏បានលើកឡើងពីកង្វល់ និងមតិយោបល់នានាទៅកាន់ថ្នាក់ដឹកនាំដោយផ្ទាល់។ ហើយថ្នាក់ដឹកនាំក៏បានធ្វើទស្សនកិច្ចទីផ្សារនៅតាមតំបន់លក់ ដើម្បីរក្សាទំនាក់ទំនងល្អជាមួយនឹងដៃគូអាជីវកម្ម ព្រមទាំងបានស្វែងយល់ពីប្រសិទ្ធភាពការអនុវត្តយុទ្ធសាស្រ្តអាជីវកម្ម និងឧបសគ្គនានាដែលមានក្នុងទីផ្សារ។ ទស្សនកិច្ចទីផ្សារនេះ ក៏ជាឱកាស មួយដែលថ្នាក់ដឹកនាំបានស្វែងយល់ពីសក្តានុពលនៃអាជីវកម្មនៅតាមតំបន់លក់ និងបានស្តាប់ពីការយល់ឃើញ និងការលើកឡើងរបស់អតិថិជនដោយផ្ទាល់ផងដែរ។

បច្ចុប្បន្នភាពអាជីវកម្ម ក៏ជួយយើងអភិវឌ្ឍយុទ្ធសាស្រ្តប្រកបដោយបរិយាបន្ន និងផ្សារភ្ជាប់ទំនាក់ទំនងបុគ្គលិក ដែលជាធនធានដ៏មានតម្លៃបំផុតរបស់ក្រុមហ៊ុន ក្នុងការសម្រេចមហិច្ឆតា និងយុទ្ធសាស្រ្ត Sail'27 របស់យើង ក៏ដូចជាជំរុញឲ្យសម្រេចគោលដៅចីរភាព ជុំវិញប្រធានបទ បរិស្ថាន សង្គម និងអភិបាលកិច្ច និងអនុលោមភាពតាមត្រីវិស័យរបស់យើង ឆ្ពោះទៅរកភាពកាន់តែល្អប្រសើរទាំងថ្ងៃនេះ និងថ្ងៃស្អែក។













# កម្មវិធីបុគ្គលិកប្រចាំខែ លើគុណតម្លៃ
# ឥរិយាបថរបស់ ខេមប្រ៊ូវ









គុណតម្លៃ និងឥរិយាបថរបស់ខេមប្រ៊ូវ ជួយគាំទ្រដល់ចក្ខុវិស័យរបស់យើងក្នុងការសម្រេចនិងបង្កើតវប្បធម៌ A ទាំងបី ទៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ ព្រមទាំងជួយរក្សាគណនេយ្យភាព នៃបុគ្គលិក ក៏ដូចជាគូសបញ្ជាក់យ៉ាងច្បាស់ថា តើខេមប្រ៊ូវ និងបុគ្គលិកទាំងអស់ត្រូវប្រតិបត្តិ និងមានឥរិយាបថយ៉ាងដូចម្ដេច។ កម្មវិធីបុគ្គលិកប្រចាំខែ លើគុណតម្លៃ និងឥរិយាបថ ត្រូវបានផ្តួចផ្តើមជាយុទ្ធសាស្ត្រដើម្បីជំរុញលើកទឹកចិត្តបុគ្គលិកឱ្យអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគុណតម្លៃ និងឥរិយាបថនៅកន្លែងធ្វើការ ក៏ដូចជាបង្កើនការចូលរួមរបស់ពួកគេក្នុងការបង្ហាញនូវការអនុវត្តគុណតម្លៃ និងឥរិយាបថនៅខេមប្រ៊ូវ។

គិតត្រឹមថ្ងៃនេះ សហសេវិកចំនួន ៦២ រូប ត្រូវបានជ្រើសរើសដោយមិត្តរួមការងារសម្រាប់ការប្រជែងយកជ័យលាភីឆ្នើម លើការអនុវត្តគុណតម្លៃ និងឥរិយាបថនៅខេមប្រ៊ូវ។ គណៈកម្មាធិការវាយតម្លៃកម្មវិធីបុគ្គលិកប្រចាំខែ បានវាយតម្លៃសម្រាំងយកបេក្ខជន ១១ រូប ដែលលេចធ្លោ ក្នុងការអនុវត្តនូវគុណតម្លៃ និងឥរិយាបថ។ បេក្ខជនទាំង ១១ រូប មកពីតួនាទី និងផ្នែកផ្សេងៗគ្នា ដូចជាផ្នែកលក់ ទីផ្សារ ហិរញ្ញវត្ថុ និងផ្នែកខ្សែសង្វាក់ផ្គត់ផ្គង់។







ក្រុមហ៊ុនសូមថ្លែងអំណរគុណដល់សហសេវិកទាំងអស់ ចំពោះការប្រកាន់ខ្ជាប់នូវឥរិយាបថប្រកបដោយភាពជាគំរូ និងនាំយកនូវការផ្លាស់ប្តូរជាវិជ្ជមានសម្រាប់ក្រុមហ៊ុនយើងទាំងមូល។ យើងកំពុងរង់ចាំ និងចង់ឃើញបេក្ខភាពបុគ្គលិកឆ្នើមជាច្រើនរូបទៀត ដែលជាបុគ្គលិកគំរូក្នុងការបង្ហាញនូវគុណតម្លៃ និងឥរិយាបថ នៅខែបន្តបន្ទាប់ទៀត។

# កម្មវិធីបណ្ដុះបណ្ដាលយុវជន ទើបបញ្ចប់ការសិក្សា




នៅកាសស្បៀរ បុគ្គលិកជាទ្រព្យដ៏មានតម្លៃបំផុតរបស់យើង ហើយយើងប្រឹងប្រែងធ្វើឲ្យមានភាពកាន់តែប្រសើរជាបន្តបន្ទាប់ ក្នុងការទាក់ទាញ រក្សា និងបង្កើនការចូលរួមរបស់បុគ្គលិក ដើម្បីធានាថា សហសេវិករបស់យើងកាន់តែពេញចិត្ត និងរីករាយជាមួយនឹងបរិយាកាសការងារនៅខេមប្រ៊ូវ។ កម្មវិធីនេះជាការបោះជំហានមួយទៀត សម្រាប់យុវជនមានទេពកោសល្យ មានមហិច្ឆតា ដែលកំពុងស្វែងរកការបណ្ដុះបណ្ដាលក្នុងអាជីពការងារនៅក្រុមហ៊ុនអន្តរជាតិ។

កម្មវិធរយៈពេល២៤ខែនេះ ត្រូវបានបង្កើតឡើង ដើម្បីអភិវឌ្ឍយុវជនឲ្យក្លាយជាអ្នកដឹកនាំនាពេលអនាគត និងផ្ដល់បទពិសោធការងារដ៏អស្ចារ្យ ដល់យុវជនមានទេពកោសល្យមានការតាំងចិត្ត នៅទូទាំងផ្នែកលក់ ទីផ្សារ ខ្សែសង្វាក់ផ្គត់ផ្គង់ ហិរញ្ញវត្ថុ និងធនធានមនុស្ស ដោយពួកគេចាប់ផ្ដើមដំណើរស្វែងយល់ និងក្រេបយកបទពិសោធការងារមិនងាយរកបានជាមួយនឹងបញ្ហាប្រឈមនានាដែលកំពុងរង់ចាំនាពេលខាងមុខ។






យើងផ្តល់លទ្ធភាពពិតប្រាកដដល់ពួកគេ ក្នុងការដកបទពិសោធ និងបង្កើតជាប្រយោជន៍ដល់អាជីពការងាររបស់ពួកគេ។ សិក្ខាកាមរបស់យើង នឹងត្រូវបំពាក់បំប៉នសមត្ថភាពយ៉ាងល្អ ទាំងជំនាញរឹងក្នុងតួនាទីមុខងារ និងជំនាញទន់ផ្ទាល់ខ្លួន ជាមួយនឹងការអនុវត្តជាក់ស្តែង ផ្ទាល់ៗជាមួយថ្នាក់ដឹកនាំ។ ពួកគេទទួលបានឱកាសប្តូរវេនធ្វើការ ក្នុងផ្នែកនីមួយៗនៅ ខេមប្រ៊ូវ ដែលពួកគេអាចស្វែងយល់ការងារពីគ្រប់ផ្នែក និងកសាងភាពជាអ្នកដឹកនាំ។










ក្នុងឆ្នាំ ២០២២ កម្មវិធីនេះ ទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសហសេវិករបស់យើង ក៏ដូចជាពីសិស្សនិស្សិតនៅតាមបណ្តាសាកលវិទ្យាល័យ និងសហគមន៍ទូទាំងប្រទេស។ កម្មវិធីនេះ បានទាក់ទាញបេក្ខជនជាង ២០០នាក់ មកពីមជ្ឈដ្ឋានផ្សេងៗគ្នា ហើយឆ្លងកាត់ការប្រលងធ្វើតេស្តយ៉ាងតឹងរ៉ឹងជាច្រើនដំណាក់កាល។ ហើយយើងក៏បានរកឃើញបេក្ខជនដែលមានទេពកោសល្យបំផុតចំនួន ៦រូប ហើយពួកគេបានចូលរួមជាមួយយើងកាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២។

**តោះ មកស្គាល់ថាពួកគាត់ជានរណា និងចូលអានសារពីពួកគាត់ទាំងអស់គ្នា។**

# Sting Metaverse ចាប់ផ្តើមហើយ

## កម្រិតបន្ទាប់ នឹងចាប់ផ្តើមនៅទីនេះ!




ចាប់តាំងពីការចាប់ផ្តើមនៃដំណើរការរបស់ ស្ទីង ពាណិជ្ជសញ្ញាមួយនេះបាននាំឱ្យយើង ក្លាយជាក្រុមហ៊ុនឈានមុខគេមួយ ក្នុងឧស្សាហកម្មភេសជ្ជៈបង្កើនថាមពល។ ឥឡូវនេះ ស្ទីង ត្រៀមរួចជាស្រេចដើម្បីបង្ហាញកំណែប្រែថ្មី និងឈានទៅកម្រិតបន្ទាប់៖ Sting Metaverse ចាប់ផ្តើមហើយ...

ឆាប់ៗនេះ ស្ទីង នឹងនាំតារាចម្រៀងដ៏ល្បីរបស់ប្រទេសថៃ Jannine Weigel រួមជាមួយនឹងតារាចម្រៀងរ៉េបដ៏ល្បីរបស់កម្ពុជា G-Devith តាមរយៈ ស្ពតពាណិជ្ជកម្ម Metaverse នៅប្រទេសកម្ពុជា និងនៅតាមទីផ្សារភេសជ្ជៈបង្កើនថាមពលមួយចំនួនក្នុងតំបន់។

នេះជាយុទ្ធនាការទីផ្សារមួយរបស់ ពាណិជ្ជសញ្ញាស្ទីង ដែលធ្វើឡើងម្តង ឬពីរដងក្នុងមួយឆ្នាំ។ យុទ្ធនាការនេះ មានផ្សាយលើគ្រប់ប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញសង្គម ដើម្បីបង្ហាញពីភាពអស្ចារ្យ ភាពរីករាយ និងការភ្ញាក់ផ្អើល ហើយកាន់តែសំខាន់ គឺបន្តការយល់ដឹងអំពីពាណិជ្ជសញ្ញាស្ទីងឱ្យកាន់តែខ្លាំងក្លា។ ស្ពតពាណិជ្ជកម្មរបស់ស្ទីង នឹងណែនាំបច្ចេកវិទ្យា GCI នៅក្នុងពិភព Avatar នៅកម្ពុជា។ យើងមានមោទកភាព ដែលស្ពតពាណិជ្ជកម្មស្ទីង Metaverse នេះ នឹងត្រូវចាក់ផ្សាយនៅក្នុងតំបន់ ដូចជាក្នុងប្រទេសឡាវ និងមីយ៉ាន់ម៉ាជាដើម។

## ភាពរំភើបរីករាយ នឹងមកដល់ឆាប់ៗនេះ...

#STINGMETAVERSE & #STINGCAMBODIA.

# ស្រាបៀរអង្គរ ៣០ឆ្នាំ នៃ កិត្យានុភាព និង នៅតែបន្ត




**រយៈពេលបីទសវត្សរ៍មកហើយ ដែលស្រាបៀរអង្គរ បាននៅជាមួយប្រជាជនកម្ពុជាជាមួយនឹងពាក្យស្លោក “ប្រទេសខ្ញុំ ស្រាបៀរខ្ញុំ”។ អរគុណអ្នកទាំងអស់គ្នា សម្រាប់ការចូលរួមក្នុងការចងចាំដ៏អស្ចារ្យ និងក្នុងដំណើររបស់ស្រាបៀរយើង។**

ផលិតជាលើកដំបូង ក្នុងឆ្នាំ១៩៩២ ហើយត្រូវបាននាំចេញទៅក្រៅប្រទេសយ៉ាងទូលំទូលាយ ស្រាបៀរអង្គរ បានក្លាយជាស្រាបៀរកំពូលរបស់ ខេមប្រ៊ូវ ដែលជាក្រុមហ៊ុនមានប្រតិបត្តិការលើរោងចក្រផលិតស្រាបៀរដំបូងគេនៅកម្ពុជា និងជាក្រុមហ៊ុនផលិតស្រាបៀរដ៏ធំបំផុតមួយ នៅតំបន់អាស៊ីអាគ្នេយ៍។ ជាមួយនឹងរសជាតិដ៏ឈ្ងុយឆ្ងាញ់ គុណភាពខ្ពស់ និងស្របតាមស្តង់ដារអន្តរជាតិ ស្រាបៀរអង្គរ បានទាក់ទាញទឹកចិត្តប្រជាជនកម្ពុជា ដៃគូពាក់ព័ន្ធ ដៃគូអាជីវកម្ម អតិថិជន និងសហគមន៍ តាមរយៈការបញ្ចូលរូបតំណាងអត្តសញ្ញាណជាតិ ទៅក្នុងយុទ្ធសាស្រ្តស្នូលនៃផលិតកម្ម និងពាណិជ្ជកម្ម។

ស្រាបៀរអង្គរ កំពុងប្រឹងប្រែងពង្រីកទីផ្សាររបស់ខ្លួន ស្របពេលដែលបន្តភាពយូរអង្វែងស្ថិតស្ថេរនៃរូបតំណាងអត្តសញ្ញាណជាតិរបស់យើង។ ព្រឹត្តិការណ៍ដ៏សំខាន់បំផុតមួយក្នុងឆ្នាំនេះ ស្រាបៀរអង្គរ បានចាប់ផ្តើមយុទ្ធនាការលើកស្ទួយបេតិកភណ្ឌជាតិ ដែលផ្តោតសំខាន់លើនិមិត្តសញ្ញាតំណាងអត្តសញ្ញាណជាតិខ្មែរ ចំនួនបួន៖




**ក្រមា៖** តម្បាញក្រមាដ៏ញឹក ដូចទំនាក់ទំនង ដែលរឹងមាំ។




**ចាប៉ីដងវែង៖** ខ្សែចាប៉ីមិនអាចខ្វះខ្សែ ដូចភាពរីករាយមិនអាចខ្វះគ្នា ។




**ដើមត្នោត៖** ដើមត្នោតលូតខ្ពស់ ដូចមិត្តភាពដ៏រឹងមាំយូរអង្វែង។




**ស្បែកធំ ៖** ពន្លឺឆ្លុះចេញជាស្រមោល ឆ្លុះបញ្ចាំងពីជីវិតដ៏រស់រវើក។

**៣០ ឆ្នាំនៃកិត្យានុភាព និងនៅតែបន្ត!**

**៣០ឆ្នាំ ដក់ក្នុងបេះដូងខ្មែរ និងនៅតែបន្ត!**

**អបអរសាទរ និងនៅតែបន្តជាច្រើនឆ្នាំបន្តបន្ទាប់ទៀត!**

# ឃួន សុភ័ក្ត្រ នឹង ចូលរួមកម្មវិធីផ្លាស់ប្តូរ បទពិសោធន៍ហិរញ្ញវត្ថុ ឆ្នាំ២០២៣



**ឃួន សុភ័ក្ត្រ** បច្ចុប្បន្នមានតួនាទីជាប្រធានគ្រប់គ្រងជាន់ខ្ពស់ផ្នែកត្រួតពិនិត្យហិរញ្ញវត្ថុ នឹងចាប់ផ្តើមបំពេញការងារក្រោមកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ហិរញ្ញវត្ថុ ឆ្នាំ២០២៣ ដោយនឹងធ្វើការក្នុងបីប្រទេសផ្សេងគ្នា។ កម្មវិធីផ្លាស់ប្តូរបទពិសោធន៍ហិរញ្ញវត្ថុរបស់កាសស៊្បែរ បង្កើតឡើង ដើម្បីផ្តល់ឱកាសដល់បុគ្គលិកក្នុងផ្នែកហិរញ្ញវត្ថុ អាចបើកសក្តានុពលរបស់ខ្លួននៅក្នុងផ្នែកហិរញ្ញវត្ថុទូទាំងកាសស៊្បែរគ្រុប ក៏ដូចជាអភិវឌ្ឍអ្នកដឹកនាំឲ្យកាន់តែខ្លាំង។ កម្មវិធីរយៈពេល ២ ឆ្នាំនេះ នឹងមានការប្តូរតួនាទីពី ២ ទៅ ៤ មុខតំណែងផ្សេងគ្នា ទៅតាមមុខងារ និងទីផ្សារ ហើយកម្មវិធីនេះ ក៏នឹងផ្តល់ចំណេះដឹងដែលផ្សារភ្ជាប់បទពិសោធន៍ និងជំនាញ ក៏ដូចជាផ្តល់ឱកាស ដើម្បីអភិវឌ្ឍវិជ្ជាជីវៈ ព្រមទាំងទទួលបានចំណេះដឹងអំពីអាជីវកម្មរបស់កាសស៊្បែរគ្រុបផងដែរ។

សុភ័ក្ត្រ ចូលរួមដំណើរជាមួយកាសស៊្បែរកម្ពុជា (ខេមប្រ៊ូវ) ក្នុងខែកក្កដា ឆ្នាំ២០១១ ក្នុងតួនាទីជាអ្នកប្រតិបត្តិផ្នែកគណនេយ្យ ហើយត្រូវបានដំឡើងតួនាទី ជាប្រធានផ្នែកគណនេយ្យ និងពន្ធ ក្នុងឆ្នាំ២០១៩។ ក្រោយមក សុភ័ក្ត្រ បានក្លាយជាប្រធានគ្រប់គ្រងផ្នែកត្រួតពិនិត្យហិរញ្ញវត្ថុ ក្នុងខែមករា ឆ្នាំ២០២១ ហើយត្រូវបានដំឡើងតួនាទីជាប្រធានគ្រប់គ្រងជាន់ខ្ពស់ ផ្នែកត្រួតពិនិត្យហិរញ្ញវត្ថុ ក្នុងខែមេសា ឆ្នាំ២០២២។ ការងារដំបូងរបស់សុភ័ក្ត្រក្រោមកម្មវិធីនេះ គឺនៅប្រទេសម៉ាឡេស៊ី ដោយនឹងត្រូវចាប់ផ្តើមក្នុងខែកុម្ភៈ ឆ្នាំ២០២៣។ បន្ទាប់មក សុភ័ក្ត្រ នឹងបន្តការងារជាមួយក្រុមការងារផ្នែកផែនការហិរញ្ញវត្ថុ និងវិភាគ នៅទីក្រុងកូផេនហាហ្គេន និងចុងក្រោយគឺនៅប្រទេសឡាវ។ កម្មវិធីផ្លាស់ប្តូរបទពិសោធន៍នេះ នឹងអាចឲ្យសុភ័ក្ត្រកសាងសមត្ថភាពផ្នែកហិរញ្ញវត្ថុ យ៉ាងទូលំទូលាយ លើសពីជំនាញហិរញ្ញវត្ថុក្នុងបរិបទក្នុងតំបន់។

សូមចូលរួមជូនពរសុភ័ក្ត្រ ទទួលបានជោគជ័យ ក្នុងកម្មវិធីផ្លាស់ប្តូរបទពិសោធន៍នេះ។

# បៃតងទាំងពិន្ទុ បៃតងទាំងឡូហ្គូ! ទាំងពីរត្រូវតែបៃតង




ខេមប្រ៊ូវ បានទទួលពិន្ទុខ្ពស់មួយដ៏គួរឲ្យរីករាយ ក្នុងដំណើរការត្រួតពិនិត្យអនុលោមភាពសុវត្ថិភាពចំណីអាហារ និងភេសជ្ជៈ ពីវិទ្យាស្ថានឃ្លាំមើលសុវត្ថិភាពចំណីអាហារសហរដ្ឋអាម៉េរិក American Institute of Bakery Food and Drinks Consultancy ។

គ្មានចន្លោះប្រហោងណាមួយ ដែលអង្គភាពឃ្លាំមើលមួយនេះបានរកឃើញនោះទេ ហើយ ៨១០ពិន្ទុ ត្រូវបានផ្តល់ឲ្យខេមប្រ៊ូវ។ នៅក្នុងតារាងកំណត់របស់អ្នកឃ្លាំមើល ពិន្ទុនេះ ធ្វើឲ្យខេមប្រ៊ូវស្ថិតក្នុងចំណាត់ថ្នាក់ពណ៌បៃតង។ នេះជាពិន្ទុ ដែលខ្ពស់ជាងគេមួយ បើគិតត្រឹមប្រមាណ១០ឆ្នាំចុងក្រោយនេះ។

អង្គភាពឃ្លាំមើលដែលបានរៀបរាប់ខាងលើនេះ គឺជាសវនករខាងក្រៅ ដែល PepsiCo ចាត់តាំងឲ្យធ្វើសវនកម្ម អំពីអនុលោមភាពសុវត្ថិភាពចំណីអាហារ លើការផលិតភេសជ្ជៈរបស់ PepsiCo ។

សម្រាប់ការឲ្យពិន្ទុ ពណ៌បៃតងសំដៅទៅលើពិន្ទុចន្លោះពី ៧០០ ដល់ ៨៩៩ ដោយបូករួមទាំងគ្មានចន្លោះប្រហោង។ ចំណែកឯ ពណ៌ខៀវសំដៅទៅលើពិន្ទុលើសពី ៩០០ ហើយពណ៌ក្រហមវិញ មានន័យថាពិន្ទុក្រោម ៧០០ ឬមានចន្លោះប្រហោង ទោះបីជាតែមួយក៏ដោយ។

យើងពិតជាសប្បាយចិត្តដោយទទួលបានពិន្ទុពណ៌បៃតងមួយនេះ ដែលដូចគ្នាទៅនឹងពណ៌ឡូហ្គូរបស់ក្រុមហ៊ុនយើងដែរ។ ប៉ុន្តែយើងនឹងមិនឈប់ត្រឹមនេះទេ! យើងនឹងបន្តដំណើរឈានទៅយកពណ៌ខៀវ នាពេលខាងមុខ!



CAMBREW LTD
Part of the Carlsberg Group



# ការទទួលស្គាល់ និងការបញ្ជាក់មានសុវត្ថិភាព រាប់ចាប់តាំងពីសម្រាំញយកវត្ថុធាតុដើមក្នុងផលិតកម្ម រហូតដល់ផលិតផលស្ថិតក្នុងដៃអ្នកប្រើប្រាស់

**FSSC 22000 Certified**

នៅ ខេមប្រ៊ូវ យើងធ្វើគ្រប់យ៉ាង ដើម្បីឆ្លើយតបនឹងការកើនឡើងនៃតម្រូវការទីផ្សារ និងនាំយកនូវផលិតផលដែលមានតម្លៃសមរម្យសម្រាប់ទីផ្សារ មានសុវត្ថិភាព មានគុណភាព សម្រាប់អតិថិជន។ ជាផ្នែកមួយនៃវិញ្ញាបនបត្រ បញ្ជាក់ប្រព័ន្ធសុវត្ថិភាពចំណីអាហារ FSSC 22000 ដែលធានាពីស្តង់ដារសុវត្ថិភាពចំណីអាហារ និងដំណើរការផលិតក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ សវនកម្ម FSSC 22000 បានប្រព្រឹត្តិឡើង នៅចន្លោះថ្ងៃទី២១ ដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២។ គ្មានការរកឃើញធំដុំណាមួយ ត្រូវបានអ្នកជំនាញជួបប្រទះនោះទេ ហើយចំណុចតូចៗ ដែលបានគេរកឃើញ ក៏ត្រូវបានក្រុមការងារផ្នែកសុវត្ថិភាពចំណីអាហាររបស់ក្រុមហ៊ុនដឹកនាំដោះស្រាយបានភ្លាមៗផងដែរ។

ក្រុមហ៊ុនយើង បានទទួលជោគជ័យនៅក្នុងសវនកម្មដំណាក់កាលទី២ នៃការឃ្លាំមើល ដែលដឹកនាំដោយអង្គភាពឃ្លាំមើល Global Food Safety Initiative។ វិញ្ញាបនបត្រ ដែលបញ្ជាក់ពីការទទួលជោគជ័យខាងលើនេះ នឹងត្រូវផ្តល់ជូនពីរខែក្រោយ បន្ទាប់ពីថ្ងៃឃ្លាំមើល។

**មកដឹង និងស្វែងយល់ពីវិញ្ញាបនបត្រនេះ ហើយហេតុអ្វីបានជាយើងត្រូវការវិញ្ញាបនបត្រនេះ?**

វិញ្ញាបនបត្រប្រព័ន្ធសុវត្ថិភាពចំណីអាហារ ឬ Food Safety System Certification 22000 (ហៅកាត់ថា FSSC 22000) គឺជាគ្រឹះស្ថាន និងអង្គការក្រៅរដ្ឋាភិបាលមួយ មានទីតាំងនៅទីក្រុង Gorinchem ប្រទេសហូឡង់ ដែលជាស្ថាប័នផ្តល់អ្នកផលិតនូវគុណសម្បត្តិ ដូចជាការធានាអំពីផលិតកម្មប្រកបដោយមេត្រីភាពបរិស្ថាន រក្សាកិត្តិសព្ទអាជីវកម្ម ក៏ដូចជាការផ្តល់ឱកាសក្នុងការពង្រីកវិសាលភាពអាជីវកម្មទៅកាន់ទីផ្សារផ្សេង ទូទាំងពិភពលោក។

CAMBREW LTD
Part of the Carlsberg Group

១៥-ធ្នូ-២០២២ /លេខ៖ CAMNOV2022#1

# តម្លាភាពជាអាទិភាពជានិច្ច

**នៅក្នុងបរិបទ ដែលមនុស្សកំពុងតែមានការយល់ដឹងអំពីបរិស្ថាន និងបម្រែបម្រួលយ៉ាងឆាប់រហ័សនៅក្នុងសង្គម ចីរភាព និងសុខុមាលភាពរបស់មនុស្ស បានក្លាយទៅជាចំណុចរួមមួយដែលទទួលបានការយកចិត្តទុកដាក់ខ្ពស់ពីក្រុមហ៊ុនអន្តរជាតិធំៗ។**

## យើងនៅ ខេមប្រ៊ូវ ក៏មិនអាចមើលរំលងពីបញ្ហានេះដែរ។

ក្នុងឆ្នាំ២០២២ ខេមប្រ៊ូវ ជាមួយនឹងក្រុមហ៊ុនផលិតស្រាបៀរកាសស៊ែរ្ស ចំនួនពីរទៀត មានដូចជាកាសស៊ែរ្សប៉ូឡូញ និងកាសស៊ែរ្សអេស្តូនី ត្រូវបានជ្រើសរើសជាទីតាំងធ្វើសវនកម្មដោយPWC លើផ្នែកមួយចំនួនដូចជា បរិស្ថាន សុខភាព &សុវត្ថិភាព គ្មានការពិសាគ្រឿងស្រវឹងដោយគ្មានទំនួលខុសត្រូវ និងពិពិធភាព សមធម៌ &បរិយាបន្ន ។

ដើម្បីឆ្លើយតបតាមការតម្រូវតាមស្តង់ដារត្រឹមត្រូវ លើការបំភាយកាបូន ការប្រើប្រាស់ថាមពលអគ្គិសនី ការគ្រប់គ្រងទឹក ការលើកកម្ពស់បុគ្គលិកជាស្ត្រីនៅក្នុងតំណែងធំៗ និងផ្នែកផ្សេងៗទៀត ត្រូវបានធ្វើសវនកម្ម។

ក្នុងឆ្នាំ ២០២២ មានការសង្កេតមួយចំនួនត្រូវបានរកឃើញដោយសវនករ តែការសង្កេតទាំងនោះ មិនមានហានិភ័យអ្វីដល់ក្រុមហ៊ុននោះទេ យើងអាចកែតម្រូវភ្លាមៗ។

ដើម្បីដើរឲ្យទាន់ទំនើបកម្មពិភពលោក ខេមប្រ៊ូវ បាន និងកំពុងសម្លឹងទៅរកការដាក់បញ្ចូលនូវប្រព័ន្ធស្វ័យប្រវត្តិឲ្យបានច្រើនជាងមុន ដើម្បីធ្វើឲ្យមានភាពកាន់តែប្រសើរឡើងក្នុងផលិតភាពការងារ កាត់បន្ថយកំហុសឆ្គងផ្សេងៗ នានារបស់មនុស្ស  ក៏ដូចជាកាត់បន្ថយចំណាយគ្មានប្រសិទ្ធភាពនានា ដែលជាប្រយោជន៍ដល់អតិថិជន។

ខេមប្រ៊ូវ បាន និងកំពុងយកចិត្តទុកដាក់ទៅលើចំណុចទាំងអស់នេះ ហើយអនុវត្តការផ្លាស់ប្តូរឲ្យមានប្រសិទ្ធភាពស្របទៅតាមផែនការហិរញ្ញវត្ថុ ផ្លូវច្បាប់ និងចក្ខុវិស័យនានា ក្នុងពេលអនាគត។




# មិនមែន«សូន្យ» ដែលអ្នកគិតនោះទេ...




ខេមប្រ៊ូវ ពិតជាមានក្ដីរំភើបជាខ្លាំង ដែលបានឈ្នះពានរង្វាន់ឧត្តមភាពទំនួលខុសត្រូវសង្គមលើផ្នែក “បរិស្ថាន” ដែលរៀបចំដោយសភាពាណិជ្ជកម្ម អាម៉េរិកនៅកម្ពុជា នៅក្នុងឆ្នាំដំបូង ដែលយើងបានក្លាយជាសមាជិករបស់សភាពាណិជ្ជកម្ម មួយនេះ ។

ដើម្បីសម្រេចគោលបំណងរបស់យើង «Brewing for A Better Today and Tomorrow ឬ ការអភិវឌ្ឍឲ្យកាន់តែប្រសើរសម្រាប់ថ្ងៃនេះ និងថ្ងៃស្អែក» ខេមប្រ៊ូវបាន និងកំពុងដឹកនាំប្រតិបត្តិការអាជីវកម្មប្រកបដោយការទទួលខុសត្រូវ និងចីរភាព។ ក្នុងការប្រកួតប្រជែងយើងបានសង្កត់ធ្ងន់ទៅលើមហិច្ឆតាជាចីរភាពរបស់យើង «រួមគ្នាឆ្ពោះទៅកាន់ហេអ្យូរ៉ូកាបូន» គឺគ្មានការបំភាយកាបូន នៅរោងចក្រផលិតរបស់យើង នៅត្រឹមឆ្នាំ ២០៣០។







ដោយហេតុថា បម្រែបម្រួលអាកាសធាតុ គឺជាប្រធានបទដែលកាន់តែតានតឹងទៅៗ ខេមប្រ៊ូវ ជឿជាក់ថា មនុស្សគ្រប់រូបប្រាថ្នាចង់រស់នៅដោយសុខដុមរមនា ជាមួយនឹងប្រព័ន្ធអេកូឡូស៊ីដ៏ល្អ ទឹកស្អាត ខ្យល់អាកាសបរិសុទ្ធ និងដីដែលពោរពេញទៅដោយជីវជាតិសម្រាប់ការដាំដុះដំណាំ។ ខេមប្រ៊ូវ ជាបុត្រសម្ព័ន្ធមួយរបស់កាសស្ប៊ែរ គ្រុប ជឿជាក់ថា ការយកចិត្តទុកដាក់ទៅលើចីរភាព នឹងជួយពង្រឹងភាពខ្លាំងដល់អាជីវកម្ម ឲ្យរីកចម្រើនជានិរន្តរភាព និងបង្កើតផលវិជ្ជមានសម្រាប់សហគមន៍របស់យើង។

#រួមគ្នាឆ្ពោះទៅកាន់ហ្សេរ៉ូ
#ការអភិវឌ្ឍឲ្យកាន់តែប្រសើរសម្រាប់ថ្ងៃនេះនិងថ្ងៃស្អែក

CAMBREW LTD
Part of the Carlsberg Group

១៥-ធ្នូ-២០២២ /លេខ៖ CAMNOV2022#1

# សុខភាព ៩សុវត្ថិភាព
## តែងតែជាអាទិភាពចម្បងរបស់យើងជានិច្ច








សុខភាព ៩សុវត្ថិភាពរបស់សហសេវិករបស់យើង តែងតែមកមុនជានិច្ច។ ការការពារសុខសុវត្ថិភាពរបស់សហសេវិកនៅគ្រប់សកម្មភាពការងារ គឺជាគុណតម្លៃស្នូលដែលពួកយើងប្រើក្នុងការដឹកនាំប្រតិបត្តិការអាជីវកម្ម។
យើងវិនិយោគទៅលើសហសេវិក ដោយកសាងជំនាញ និងបទពិសោធជាក់ស្តែង។ ការអនុវត្តការងារដែលមិនមានសុវត្ថិភាព ផ្តល់គ្រោះថ្នាក់ដល់សហសេវិក និងប៉ះពាល់ដល់អាជីវកម្មរបស់យើង។ អាជីវកម្មរបស់យើងរីកចម្រើន អាស្រ័យលើសុខសុវត្ថិភាព និងសុខុមាលភាពរបស់សហសេវិក។ យើងចង់ឃើញសហសេវិកទាំងអស់ត្រឡប់ទៅផ្ទះវិញប្រកបដោយសុខសុវត្ថិភាពជារៀងរាល់ថ្ងៃ។ មហិច្ឆតា «រួមគ្នាឆ្ពោះទៅកាន់ហេដ្ឋរ៉ូគ្រោះថ្នាក់ ឬគ្មានវប្បធម៌គ្រោះថ្នាក់» បានកំណត់ក្នុងប្រធានបទបរិស្ថាន សង្គម និងអភិបាលកិច្ចរបស់យើង គឺ «រួមគ្នាឆ្ពោះទៅកាន់ហេដ្ឋរ៉ូ (TTZ)»។ តាមរយៈមហិច្ឆតានេះ យើងមានការប្តេជ្ញាខ្ពស់ក្នុងការកាត់បន្ថយគ្រោះថ្នាក់ប្រចាំឆ្នាំ ឆ្ពោះទៅកាន់ហេដ្ឋរ៉ូគ្រោះថ្នាក់ នៅត្រឹមឆ្នាំ ២០៣០។






យើងជឿជាក់ថា គ្រោះថ្នាក់គ្រប់ទម្រង់ទាំងអស់ នឹងមិនកើតមានឡើង ហើយវប្បធម៌គ្មានគ្រោះថ្នាក់របស់យើង ដើរតួយ៉ាងសំខាន់ក្នុងការបង្កើតទីកន្លែងការងារមានសុវត្ថិភាព។ យើងនឹងទទួលជោគជ័យ បើយើងទុកសុខភាព ៩សុវត្ថិភាពជាអាទិភាពគ្រប់ពេលវេលាជានិច្ច។ ភាពជាគំរូ និងការចូលរួមពីសហសេវិកគ្រប់រូប អំពីសុខភាព ៩សុវត្ថិភាព នឹងនាំឲ្យយើងសម្រេចបានមហិច្ឆតានេះ។

កម្មវិធីប្រកួតប្រជែង «ជើងឯកសុខសុវត្ថិភាព» របស់យើង គឺជាឧទាហរណ៍គំរូមួយ ដែលផ្តួចផ្តើមឡើង ក្នុងគោលបំណងបង្កើនការយល់ដឹង និងបង្កើនកិច្ចសន្ទនារបស់បុគ្គលិកស្ដីពីសុខភាព ៩សុវត្ថិភាព ក៏ដូចជាចូលរួមចំណែកក្នុងការបង្កើតបរិយាកាសការងារមានសុវត្ថិភាព ឆ្ពោះទៅកាន់វប្បធម៌គ្មានគ្រោះថ្នាក់នៅកន្លែងការងាររបស់យើង។

CAMBREW LTD
Part of the Carlsberg Group

# អភិវឌ្ឍឲ្យកាន់តែប្រសើរ

១៨៨១, មហាវិថីសហព័ន្ធរុស្ស៊ី ភូមិតាងួន សង្កាត់កាកាប, ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

+៨៥៥ (០) ២៣ ៩៨៧ ៩០៥

info.kh@carlsberg.asia

www.instagram.com/cambrewltd/

www.facebook.com/CambrewCompany

www.carlsberggroup.com/
www.cambrew.com.kh/

www.linkedin.com/company/carlsbergcambodia/

# ទាំងថ្ងៃនេះ & ថ្ងៃស្អែក